

ទទួលរងនូវ

# ការបៀតបៀនផ្លូវភេទ?

## ដឹងពីសិទ្ធិរបស់អ្នក

សិស្សនិស្សិតនិងបុគ្គលិកត្រូវបានការពារប្រឆាំងនឹងអំពើបៀតបៀនផ្លូវភេទបង្កឡើងដោយជនណាម្នាក់ នៅក្នុងកម្មវិធី ឬសកម្មភាពណាមួយរបស់សាលា រួមទាំងនៅក្នុងបរិវេណសាលា នៅលើរថយន្តក្រុង ឬនៅក្រៅបរិវេណសាលា ដូចជាដំណើរសិក្សាដែលឧបត្ថម្ភដោយសាលាជាដើម។

### អ្វីទៅជាអំពើបៀតបៀនផ្លូវភេទ?

អំពើបៀតបៀនផ្លូវភេទគឺជាទំនាក់ទំនងឬកិរិយាបទឆ្គាំឆ្គងដែលមានលក្ខណៈផ្លូវភេទនៅពេលដែល៖

- សិស្សនិស្សិតឬនិយោជិកណាម្នាក់ត្រូវបានគេធ្វើឲ្យយល់ឃើញថា ខ្លួនត្រូវតែយល់ព្រមឬទទួលយកទំនាក់ទំនង ឬទង្វើឆ្គាំឆ្គងផ្លូវភេទ ដើម្បីទទួលបានអ្វីមួយជាថ្នូរ ដូចជាឡើងថ្នាក់ ឡើងឋានៈ កន្លែងមួយក្នុងក្រុមកីឡា ឬការសម្រេចណាមួយទាក់ទងនឹងការអប់រំឬការងារ ឬ
- ទង្វើនោះជ្រៀតជ្រែកយ៉ាងខ្លាំងដល់លទ្ធផលសិក្សារបស់សិស្សនិស្សិតណាម្នាក់ ឬបង្កជាការគំរាមកំហែង ឬស្ថានភាពលំបាកខ្លាំងដែលប៉ះពាល់ដល់ការសិក្សា និងការងារ។

### តើខ្ញុំរាយការណ៍អំពីការបៀតបៀនផ្លូវភេទតាមរបៀបណា?

អ្នកអាចរាយការណ៍អំពីការបៀតបៀនផ្លូវភេទប្រាប់បុគ្គលិកសាលាណាម្នាក់ ឬមន្ត្រីទទួលបន្ទុកផ្នែកបៀតបៀនផ្លូវភេទ (Title IX Officer) របស់ស្រុក៖

*ដើម្បីទទួលបានឯកសារស្តីពីគោលនយោបាយ និងនីតិវិធីទាក់ទងនឹងការបៀតបៀនផ្លូវភេទនៅស្រុករបស់លោកអ្នក សូមទាក់ទងមកកាន់ការិយាល័យរបស់សាលា ឬការិយាល័យស្រុករបស់អ្នក។*

### ឧទាហរណ៍នៃការបៀតបៀនផ្លូវភេទ៖

- ការដាក់សម្ពាធលើបុគ្គលណាម្នាក់ដើម្បីសេចក្តីគាប់ផ្លូវភេទ
- ការប៉ះពាល់ដែលមានលក្ខណៈផ្លូវភេទដោយគ្មានការព្រមព្រៀង
- ការសរសេរនៅតាមទីសាធារណៈដែលមានលក្ខណៈផ្លូវភេទ
- ការចែកចាយអត្ថបទដែលលក្ខណៈផ្លូវភេទយ៉ាងច្បាស់ ដូចជាអ៊ីម៉ែល ឬរូបភាព។
- បង្កើតរឿងកំប្លែង ពាក្យចចាមអារ៉ាម ឬកំណត់សម្គាល់ជាយោបល់ដែលមានលក្ខណៈផ្លូវភេទ។
- អំពើហិង្សាលើរាងកាយ រួមមានការចាប់ រំលោភ និងការបំពានផ្លូវភេទ។


**OSPI Equity and Civil Rights Office**
360.725.6162
equity@k12.wa.us
www.k12.wa.us/equity


Equal Access and Opportunities for Students and Educators
Equity & Civil Rights
PROMOTING EDUCATIONAL EXCELLENCE FOR ALL

SUPERINTENDENT OF PUBLIC INSTRUCTION WASHINGTON


OSPI និងសាលារដ្ឋថ្នាក់ស្រុក (school district) មិនអាចរើសអើងដោយសំអាងទៅលេ ភេទ ជាតិសាសន៍ ពណ៌ សម្បុរ ជំនឿ សាសនា ជាតិកំណើត ភេទ អាយុ ពិការភាព ស្ថានភាពគ្រួសារ ទំនោរផ្លូវភេទ ការសម្តែងនិងអត្តសញ្ញាណភេទ អតីតយុទ្ធជនឬឋានៈក្នុងផ្នែកយោធា ឬជនពិការដែលប្រើប្រាស់សេវាសត្វពាហនៈជាមធ្យោបាយ និងត្រូវតែផ្តល់ភាពស្មើគ្នាចំពោះក្រុមយុវជនទាំងអស់ដែលបានកំណត់។ បើមានសំណួរ ឬការតវ៉ា សូមអញ្ជើញទាក់ទងសាលារដ្ឋថ្នាក់ស្រុក ឬ OSPI's Equity និងCivil Rights Office តាមរយៈ P.O. Box 47200, Olympia, WA 98504 ឬទូរស័ព្ទលេខ (360) 725-6162។


CAMBODIAN